**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា**

**ប្រចាំនៅទីក្រុងណាននីង**

លេខ 0099 កពណក.ណន

**សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**<u>កម្មវត្ថុ</u>: របាយការណ៍ ប្រចាំខែ ឧសភា ឆ្នាំ ២០១២**

សេចក្តីដូចបានជំរាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយស គោរពជូន **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ប្រចាំខែ ឧសភា ឆ្នាំ២០១២ ដ៏ខ្ពង់ខ្ពស់ដូចតទៅ:

I. **ការងារទំនាក់ទំនងគ្នៀវ:**

- ជួបក្រុមហ៊ុន RONGDU PAINT មានបំណងស្វែងរកទីផ្សារលក់ថ្នាំលាបផ្ទះនិងមានទិសដៅបង្កើតរោងចក្រផលិតថ្នាំលាបផ្ទះនៅកម្ពុជា ។
- ជួបក្រុមហ៊ុន KAR TAT GROUP មានបំណងចូលរួមពិពរណ៍ពាណិជ្ជកម្មនៅកម្ពុជាក្នុងខែធ្នូ២០១២ ខាងមុខនេះ ។
- ចូលរួមដំណើរទស្សនកិច្ចសិក្សាតាមបណ្តាក្រុងឧស្សាហកម្មសំខាន់ៗនៅក្នុងខេត្តក្វាងស៊ី ដែលរៀបចំឡើងដោយមន្ទីរការបរទេសក្វាងស៊ី ។
- ចូលរួមពិពរណ៍ធនធានរ៉ែដែលរៀបចំឡើងដោយ CABIS ថ្ងៃទី១១-១៣ ខែឧសភា ឆ្នាំ២០១២ ។
- ជួបក្រុមហ៊ុន Tianjin Precious Metals Exchange មានបំណងវិនិយោគទុនរោងចក្រផលិតសំភារៈការិយាល័យនៅកម្ពុជា ។
- ជួបក្រុមហ៊ុន Guangxi Nanning Kuozhan មានបំណងបង្កើតគេហទំព័រពាណិជ្ជកម្មរវាងកម្ពុជា-ចិន ។
- ជួបក្រុមហ៊ុន Shandong Huasheng Investment Co.Ltd មានបំណងស្វែងរកដីក្នុងការវិនិយោគលើដំណាំកៅស៊ូនៅកម្ពុជា ។
- ជួបក្រុមហ៊ុន Tianyi Investment និង Guangxi Tianyi Forestry Co.Ltd មានបំណងស្វែងរកដីសម្បទានដាំស្រូវនៅកម្ពុជា ។
- ជួបក្រុមហ៊ុន Gold Jinyu មានបំណងវិនិយោគទុនលើវិស័យរ៉ែមាសនៅកម្ពុជា ។

*Address: No 11, Zhujin Road, China-ASEAN Business District, Nanning City, Guangxi, China*
*Tel/Fax: +86-771-5389496*
*Email : clo_cambodia@yahoo.com*

## II. សភាពការណ៍សេដ្ឋកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន:

ចិនជាមហាអំណាចសេដ្ឋកិច្ចចាត់ចំណាត់ថ្នាក់ទី២នៅក្នុងពិភពលោកបន្ទាប់ពីសហរដ្ឋអាមេរិក ។ តម្រូវការទីផ្សារនៅចិនមានរូបភាពធំជាងគេ ។ ជាក់ស្តែងនៅក្នុង ឆ្នាំ២០១០ចិនបាននាំចូលសណ្តែកសៀងពីសហរដ្ឋអាមេរិកដែលមានបរិមាណចំនួន១៣,៤លានតោនដែលមាន ទឹកប្រាក់ស្មើនឹង ៦,៧កោដិដុល្លា ។ ក្រៅពីសហរដ្ឋអាមេរិក ចិនបាននាំចូលសណ្តែកសៀងពីអាមេរិកខាងត្បូងមានប្រេស៊ីលនិងប្រទេសអាហ្សង់ទីនជាដើម ។ ផ្អែកតាមរបាយការណ៍របស់ក្រសួងកសិកម្មចិនបានឱ្យដឹងថា ចិនបាននាំចូលគ្រាប់ធញ្ញជាតិពីបរទេសចំនួន១០,៣% ។

នៅក្នុងឆ្នាំ២០១២នេះកំណើនផលិតផលឧស្សាហកម្មចិនកើនឡើងយឺតៗ ។ ជាក់ស្តែងនៅក្នុងខែមិនា ឆ្នាំ២០១២ ការនាំចេញរបស់ចិនកើនបានតែ៨,៩%ស្មើនឹង១៦៥,៦៦កោដិដុល្លា ឯការនាំចូលវិញសំរេចបាន១៦០,០៣១កោដិដុល្លា ។ ដោយឡែកនៅក្នុងខែមេសា ឆ្នាំ២០១២ការនាំចេញរបស់ចិនកើនបានតែ៤,៩%ស្មើនឹង១៦៣,២៥កោដិដុល្លា ។ នៅក្នុងត្រីមាសទី១ ឆ្នាំ២០១២សេដ្ឋកិច្ចចិនកើនឡើងយឺតៗ បានតែ៨,១%តែប៉ុណ្ណោះ ។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១២ ឱនភាពពាណិជ្ជកម្មចិនមានចំនួន៣១,៤៨កោដិដុល្លា បើប្រៀបធៀបជាមួយខែកុម្ភៈឆ្នាំ២០១១ មានការកើនឡើង ។ ដោយឡែកនៅក្នុងខែមិនាឆ្នាំ២០១២ឱនភាពពាណិជ្ជកម្មកើនបន្ថែមបាន៣,៦%ស្មើនឹង៣,២កោដិដុល្លា ដោយការកើនឡើងតំលៃប្រេងឥន្ធនៈនិងតម្លៃម្ហូបអាហារ ។ ដោយឡែកចំពោះតំលៃសំភារៈប្រើប្រាស់ប្រចាំថ្ងៃខែមិនា ឆ្នាំ២០១២កើនបាន៣,៦%ខ្ពស់ជាងខែកុម្ភៈ ឆ្នាំ២០១២ ដែលកើនបានតែ៣,២%តែប៉ុណ្ណោះ ។

សេចក្តីដូចបានជំរាបជូនខាងលើ សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ប្រចាំខែឧសភា ឆ្នាំ២០១២ ដោយអនុគ្រោះបំផុត ។

សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

ក្រុងណាននីង, ថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០១២

**ទីប្រឹក្សាពាណិជ្ជកម្ម**

**អ៊ុច គឹមយ៉ុន**

<u>ចម្លងជូន:</u>

-ស្ថានអគ្គកុងស៊ុលប្រចាំនៅណាននីង

-ឯកសារកាលប្បវត្តិ

*Address: No 11, Zhujin Road, China-ASEAN Business District, Nanning City, Guangxi, China*

*Tel/Fax: +86-771-5389496*

*Email : clo_cambodia@yahoo.com*